# ទំនាយប្រចាំថ្ងៃទាំង៧

## ថ្ងៃអាទិត្យ

+មនុស្សប្រុស-ស្រីណាដែលកើតថ្ងៃអាទិត្យនេះ ទំនាយទាយថាជាមនុស្សមានភ័ព្វសំណាល្អ មិនសូវលោភលន់នឹងទ្រព្យសម្បត្តិ ចេះមានគំនិតសន្សំសំចៃ ចេះមានចិត្តស្រឡាញ់រាប់អានបងប្អូន មានប្រាជ្ញាឈ្លាសវៃ និងមានចិត្តមោះមុតក្លាហាន ពុះពារគ្រប់ឧបសគ្គ អ្នកនោះជាអ្នកមានវេហាហ៍ ចរចាពិរោះ វាសនា បុណ្យសក្តិកើតឡើងដោយសារការប្រឹងប្រែងរបស់ខ្លួនជាមនុស្សសំបូរទៅដោយមិត្តភក្តិជាច្រើន ។

បុគ្គលពួកនេះគួរប្រើសំលៀកបំពាក់ពណ៌ក្រហម ទើបសមគួរ ។

## ថ្ងៃ ច័ន្ទ

(រូបមនុស្សស្រី)

+មនុស្សប្រុស-ស្រីណាដែលកើតថ្ងៃច័ន្ទនេះ ទំនាយទាយថា ជាមនុស្សអភ័ព្វញាតិការ ចិត្តច្រើន ងាករេបើសេពគប់មិត្តភក្តិល្អតែមុនដំបូង លុះចុងក្រោយទៅច្រើនសោះអង្គើយដាក់គ្នា ។ ជាមនុស្សជួយយកអាសារគេ មិនបាននាំឱ្យមានទុក្ខទោសដល់ខ្លួន លាភសក្ការៈបានមកទុកដាក់មិនសូវគង់វង្ស តែជាមនុស្សមានថ្វីមាត់ និយាយស្តីអ្វីច្រើនមានគេយកចិត្តទុកដាក់ស្តាប់ បុគ្គលពួកនេះគួរប្រើសំលៀកបំពាក់ពណ៌លឿង ទើបសមគួរ ។

## ថ្ងៃ អង្គារ

+មនុស្សប្រុស-ស្រីណាដែលកើតថ្ងៃអង្គារនេះ ទំនាយទាយថា ជាមនុស្សមានចិត្តស្លូតបូតនឹងហ្មត់ លាភសក្ការៈច្រើនរកបានដោយការប្រឹងប្រែងរបស់ខ្លួន អាចរក្សាទ្រព្យសម្បត្តិគង់វង្ស ជាមនុស្សមានសំដីចរចាពិរោះគួរជាទីស្រឡាញ់នៃអ្នកផងទាំងពួង តែពឹងពាក់អ្នកដទៃមិនបាន បុគ្គលពួកនេះគួរប្រើសំលៀកបំពាក់ពណ៌ក្រហមជាំ ទើបសមគួរ ។

## ថ្ងៃ ពុធ

+មនុស្សប្រុស-ស្រីណាដែលកើតថ្ងៃពុធនេះ ទំនាយទាយថា ជាមនុស្សមានភ័ព្វសំណាង សល់ទ្រព្យសម្បត្តិច្រើន ជាមនុស្សមានគំនិតសន្សំសំចៃ ។ ជាមនុស្សសេពគប់មិត្តភក្តិច្រើនមិនសូវសមប្រកប

មានគេច្រណែនឈ្នានីសនិទ្ទា ។ ជាមនុស្សមើលស្រាលចំពោះការងារ បុគ្គលពួកនេះធ្វើគុណដល់គេ ច្រើនបានទោសមកវិញ ។ បុគ្គលពួកនេះគួរប្រើសំលៀកបំពាក់ពណ៌ ស្លឹកឈើចាស់ ទើបសមគួរ ។

## ថ្ងៃ ព្រហស្បតិ៍

+មនុស្សប្រុស-ស្រីណាដែលកើតថ្ងៃព្រហស្បតិ៍នេះ ទំនាយទាយថា ជាមនុស្សប្រកបដោយចំណេះវិជ្ជាខ្ពង់ខ្ពស់ មានប្រាជ្ញាឈ្លាសវៃ ជាមនុស្សសំដីតិច មិនសូវចូលចិត្តចរចាច្រើនឥតប្រយោជន៍ ញាតិផងទាំងពួងចោមស្រឡាញ់រាប់អាន ជាមនុស្សដែលមានចិត្តអង់អាចក្លាហាន ហ៊ានពុះពារគ្រប់ឧបសគ្គ តែជាមនុស្សចូលចិត្តលេងល្បែងភ្នាល់ផ្សេងៗ ។ បុគ្គលពួកនេះគួរប្រើសំលៀកបំពាក់ពណ៌ស្វាទុំ ទើបសមគួរ ។

## ថ្ងៃ សុក្រ

+មនុស្សប្រុស-ស្រីដែលកើតថ្ងៃសុក្រនេះ ទំនាយទាយថា ជាមនុស្សដែលមានគូរច្រើន បើប្រុសវិញច្រើនធ្វើឱ្យស្រីៗចូលចិត្ត និងមានគេនាំលាភយកមកឱ្យជារឿយៗ ជាមនុស្សប្រកាន់នូវពាក្យសម្តីរបស់ខ្លួន កាលនៅពីតូចអភ័ព្វញាតិការ លុះធំឡើងកាលណាទើបសំបូរទៅដោយទ្រព្យសម្បត្តិថ្កុំថ្កើងរុងរឿងឡើងវិញ ។ បុគ្គលពួកនេះគួរប្រើសំលៀកបំពាក់ពណ៌ត្រាវ ឬ ពណ៌ស ទើបសមគួរ ។

## ថ្ងៃសៅរ៍

+មនុស្សប្រុស-ស្រីណាដែលកើតថ្ងៃសៅរ៍នេះ ទំនាយទាយថា ជាមនុស្សដែលមានចិត្តកំណាញ់តែចេះយកចិត្តគាប់គួរចំពោះអ្នកដទៃ ធ្វើការអ្វីៗខ្ជីខ្ជារ ច្រើនតមទាស់ តមាត់ចំពោះបងប្អូនឯង ។ ចង់សេពគប់មិត្តភឿនទឹងនាំឱ្យទុក្ខភ័យដល់ខ្លួន ។ និយាយស្តីអ្វីច្រើនជឿទុកចិត្តលើគេ ។ បុគ្គលពួកនេះគួរប្រើសំលៀកបំពាក់ពណ៌ស្វាយ ទើបសមគួរ ។